សុន្ទរកថារបស់**លោក ហ៊ីឡូជិ យ៉ូស៊ីហ៊ីរ៉ូ**

ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង

សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

១៩ កុម្ភៈ ២០១៣

- **សូមគោរព លោកស្រី អាយូមី ម៉ាត់ស៊ូរ៉ា នាយិកាអង្គការអាយ.វី.វ៉ាយ!**
- **សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនជាមួយអ្នកតំណាងនៃអង្គការ អាយ.វី.វ៉ាយ សម្រាប់គម្រោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទតាមរយៈការបង្កើតនូវការគ្រប់គ្រងដែលមាននិរន្តរភាពក្នុងសហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង (SAC)។

គម្រោងនេះមានគោលដៅលើកស្ទួយផលិតកម្មបន្លែធម្មជាតិ មិនប្រើសារធាតុគីមី និងធ្វើឲ្យមាននូវនិរន្តរភាពក្នុងបណ្តាញផ្គត់ផ្គង់ ហើយជាងនេះទៅទៀត គឺដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាពរបស់SACដើម្បីឲ្យសហគមន៍នេះមានលទ្ធភាពបន្តប្រតិបត្តិការដោយខ្លួនឯងប្រកបដោយនិរន្តរភាពនៅពេលគម្រោងនេះត្រូវបានបញ្ចប់។

តាមរយៈគម្រោងនេះ អង្គការ អាយ.វី.វ៉ាយ នឹងជួយគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាពរបស់SAC ផ្តល់ការបណ្តុះបណ្តាលជាច្រើនដល់សហគមន៍SACដែលរួមមានជាអាទិ៍ ការដាំដុះបន្លែដែលមិនមានសារធាតុគីមី វិធីសាស្ត្រផ្សព្វផ្សាយជាសាធារណៈសម្រាប់ ផលិតផលរបស់ពួកគេ ផែនការអាជីវកម្ម និង ការរក្សាទុកបញ្ជីគណនេយ្យជាដើមដល់សមាជិកនៃសហគមន៍SACដើម្បីឲ្យសមាជិកម្នាក់ៗអាចចូលរួមយ៉ាងសកម្មក្នុងដំណើរការរបស់សហគមន៍។ ជាងនេះទៅទៀត ច្រកសម្រាប់ដឹកជញ្ជូន និង ចែកចាយផលិតផលកសិកម្មរបស់សហគមន៍SACក៏នឹងត្រូវបានបង្កើតឡើងក្នុងគម្រោងនេះផងដែរ។ លើសពីនេះទៅទៀត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តបានចូលរួមក្នុងសកម្មភាពរបស់SACចាប់តាំងពីSACត្រូវបានបង្កើតឡើងម្ល៉េះ ដូចនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងមានជាបន្តទៀតផងដែរក្នុងគម្រោងនេះ។

កិច្ចសន្យាផ្តល់ជំនួយថ្ងៃនេះមានទឹកប្រាក់សរុបចំនួន ¥១៩,៨១៥,៣៧៦ ដែលស្មើនឹង ២៣៩,៦៩៦ដុល្លាអាមេរិកសម្រាប់ការអនុវត្តគម្រោងនេះ។

ការពង្រឹងវិស័យកសិកម្ម គឺជាគោលដៅមួយដ៏សំខាន់សម្រាប់អនាគតរបស់ប្រទេសកម្ពុជា ដែលជាប្រទេសកសិកម្មមួយ ហេតុដូចនេះហើយបានជារាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យនេះជាមុំមួយក្នុងបណ្តាមុំទាំងបួននៃយុទ្ធសាស្ត្រចតុកោណដើម្បីអភិវឌ្ឍន៍ជាតិ។ ដោយអនុលោមតាមគោលការណ៍នេះ រដ្ឋាភិបាលជប៉ុនបាន និងកំពុងបន្តផ្តល់ការគាំទ្រដល់វិស័យកសិកម្មនៅប្រទេសកម្ពុជាតាមរយៈការកែលម្អ និង ស្តារប្រព័ន្ធធារាសាស្ត្រ ការផ្តល់ជំនួយផ្នែកបច្ចេកទេសសម្រាប់អភិវឌ្ឍន៍ការគ្រប់គ្រងផ្នែកកសិកម្មដោយជំនួយអភិវឌ្ឍន៍ផ្លូវការនានា។ យ៉ាងណាមិញ សេវាគមនាគមន៍ការប្រមូលនិងដឹកជញ្ជូនកសិផលនៅមានកម្រិតនៅឡើយដែលយើងសង្ឃឹមថាគម្រោងនេះនឹងជួយគាំទ្របន្ថែមដល់បញ្ហានេះ។

អង្គការ អាយ.វី.វ៉ាយ ដែលជាភាគីទទួលជំនួយក្នុងថ្ងៃនេះបានចាប់ផ្តើមសកម្មភាពរបស់ខ្លួនក្នុងការគាំទ្រដល់វិស័យកសិកម្មក្នុងខេត្តស្វាយរៀងតាំងពីឆ្នាំ១៩៩៩។ ខ្ញុំបានដឹងថាសហគមន៍SACដែលទទួលបានជំនួយឧបត្ថម្ភនៅថ្ងៃនេះត្រូវបានបង្កើតឡើងដោយកសិករដាំបន្លែដែលមកពីភូមិចំនួន៦០ក្នុងខេត្តស្វាយរៀងដោយមានការជួយជ្រោមជ្រែងពីអង្គការអាយ.វី.វ៉ាយក្នុងឆ្នាំ២០១០ ហើយសហគមន៍នេះបានចុះបញ្ជីជាផ្លូវការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាសហគមន៍កសិកម្មក្នុងឆ្នាំ២០១១។

បច្ចុប្បន្ននេះសហគមន៍បានផ្គត់ផ្គង់ទៅដល់ហាងបន្លែជាច្រើននៅរាជធានីភ្នំពេញនូវបន្លែធម្មជាតិ មិនមានសារធាតុគីមីរបស់ពួកគេ។ តាមរយៈការបង្កើតសហគមន៍ផ្គត់ផ្គង់កសិផលក្នុងខេត្តស្វាយរៀងនេះ ប្រជាជនដែលកំពុងធ្វើចំណាកស្រុកទៅធ្វើការនៅភ្នំពេញហើយដោយសារតែប្រាក់បៀវត្សទាបអាចវិលត្រឡប់មកចូលរួមក្នុងវិស័យកសិកម្ម និងនេសាទវិញដោយសារតែមានការផ្លាស់ប្តូរបណ្តាញផ្គត់ផ្គង់កសិផលនេះ។ យើងសង្ឃឹមយ៉ាងមុតមាំថាសហគមន៍SACនឹងអាចដាំដុះបន្លែធម្មជាតិមិនមានសារធាតុគីមី ព្រមទាំងមានបណ្តាញផ្គត់ផ្គង់ដោយខ្លួនឯងប្រកបដោយនិរន្តរភាព ហើយសហគមន៍SACនឹងក្លាយជាគំរូមួយសម្រាប់សហគមន៍ផ្គត់ផ្គង់កសិផលក្នុងប្រទេសកម្ពុជា។

ជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន គឺផ្តល់ជូនអង្គការក្រៅរដ្ឋាភិបាលជប៉ុនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជននៅកម្រិតមូលដ្ឋាន។ ឆ្នាំនេះជាខួបលើកទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងផ្តល់អត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជននៅក្នុងតំបន់គោលដៅ ព្រមទាំងរួមចំណែកជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងជប៉ុន និង កម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!